

# សន្និសីទទូទៅ *ដ៏ពិសេស* មួយ

ដោយអាឡេលី ក្ល៉េណេល-កាមីតាន់
( ផ្អែកទៅលើដំណើររឿងពិត )

*ប្រហែលជាការជួយអាចធ្វើឲ្យនាងសប្បាយចិត្តដូចដែលប្រធាន ណិលសុន បានមានប្រសាសន៍ ។*

*ដំណើររឿងនេះបានកើតឡើងនៅប្រទេសឥណ្ឌូនេស៊ី ។*

« អាមីណា នោះជារបស់បងទេ ! » អ៊ីនឌីរ៉ា បានស្រែក ។ នាងបានចាប់ទាញតុក្កតានោះចេញពីប្អូនស្រីតូចរបស់នាង ។

ម៉ាក់បានហៅ « កូនៗ ម៉ាក់ទៅហើយ » ។ « សូមធ្វើជាកូនល្អដល់ប៉ារបស់កូនណា៎ » ។

អ៊ីនឌីរ៉ា បានងើបមុខឡើង ។ « តើម៉ាក់ទៅណា ? »



« ម៉ាក់ទៅផ្សារ ម៉ាក់ទៅទិញម្ហូបដើម្បីចម្អិនអាហារពិសេសសម្រាប់ថ្ងៃស្អែកនេះ » ។ ម៉ាក់បានត្រឡប់ដែល ។

អាហារពិសេស ? ប៉ុន្តែតើដោយសារមូលហេតុអ្វីទៅ ? អ៊ីនឌីរ៉ា បានទៅរកប៉ា ។ « ហេតុអ្វីថ្ងៃស្អែកនេះជាថ្ងៃពិសេស ? » នាងបានសួរ ។

ប៉ាបានញញឹម « ថ្ងៃស្អែកនេះ យើងទៅមើលសន្និសីទទូទៅ ! វាពិសេសដោយសារយើងអាចស្ដាប់ព្យាការី និងថ្នាក់ដឹកនាំសាសនាចក្រផ្សេងទៀតមានប្រសាសន៍ ។ ពួកលោកនឹងប្រាប់យើងពីអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងឮ » ។

ពេលម៉ាក់មកដល់ផ្ទះវិញ គាត់បានទុកដាក់ម្ហូបអាហារ ។ ប៉ាបោសជូតផ្ទះ ។

« អ៊ីនឌីរ៉ា តើកូនអាចជួយអាមីណារៀបចំសម្លៀកបំពាក់របស់នាងសម្រាប់ថ្ងៃស្អែកបានទេ ? » ម៉ាក់បានសួរ ។

អ៊ីឌីរ៉ា បានជ្រួញចិញ្ចើម « ហេតុអ្វីបានជាខ្ញុំត្រូវជួយនាងនោះ ? »

ម៉ាក់បាននិយាយ « សូមធ្វើអ្វីដែលម៉ាក់បានប្រាប់ឲ្យធ្វើទៅ » ។

អ៊ីនឌីរ៉ា បានក្ដួញក្ដែរ ។ នាងបានដើរអូសជើង ហើយទៅជួយអាមីណា ។

នៅព្រឹកស្អែក អ៊ីនឌីរ៉ា បានភ្ញាក់ឡើងដោយសារផ្លុំក្លិនឈ្ងុយម្ហូប ។ នាងបានក្រោកចេញពីគ្រែ ហើយរត់សំដៅទៅផ្ទះបាយ ។ ម៉ាក់បានធ្វើការីសាច់គោ និងសាច់អាំងទឹកជ្រលក់សណ្ដែកដីសម្រាប់អាហារថ្ងៃត្រង់ ! វានឹងមានរសជាតិឆ្ងាញ់ណាស់ ។





មិនយូរប៉ុន្មាន សន្និសីទទូទៅបានចាប់ផ្ដើម ។ អ៊ីនឌីរ៉ា អង្គុយជាមួយគ្រួសាររបស់នាងដើម្បីមើលសន្និសីទទូទៅលើកញ្ចក់ទូរទស្សន៍ ។ នាងបានស្ដាប់ក្រុមចម្រៀងច្រៀង ។ នាងបានឮមនុស្សនិយាយអំពីព្រះវិហារបរិសុទ្ធ និងព្រះគម្ពីរ ហើយនិងព្រះយេស៊ូវគ្រីស្ទ ។ អ្នកឡើងនិយាយចុងក្រោយគេ គឺព្យាការី ប្រធាន រ័សុល អិម ណិលសុន ។ លោកបាននិយាយអំពីរបៀបដែលសាសនាចក្រជួយមនុស្សនៅជុំវិញពិភពលោក ។

លោកបានមានប្រសាសន៍ « *អំណរដ៏មហិមាបំផុតរបស់យើង* កើតមានពេលយើងជួយបងប្អូនប្រុសស្រីរបស់យើង » ។[1]

អ៊ីនឌីរ៉ា បានគិតអំពីរឿងនោះ ។ តើការជួយធ្វើឲ្យនាងសប្បាយចិត្តឬ ? នាងបានបន្តស្ដាប់ ។ ប្រធាន ណិលសុន បានមានប្រសាសន៍ថាការរស់នៅតាមបញ្ញត្តិធំទីពីរនេះ អាចជួយយើងឲ្យក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ ។

នៅពេលសន្និសីទបានបញ្ចប់ ពួកគេបានញ៉ាំអាហារថ្ងៃត្រង់ដែលម៉ាក់បានធ្វើ ។ អ៊ីនឌីរ៉ា បានបន្តគិតអំពីប្រសាសន៍របស់ព្យាការី ។

« តើបញ្ញត្តិធំទីពីរជាអ្វី ? » នាងបានសួរ ។

លោកប៉ាបាននិយាយថា « ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ។[2]

អ៊ីនឌីរ៉ា បានគិតអំពីមនុស្សដែលសាសនាចក្របានជួយនៅទូទាំងពិភពលោក ។ « តើខ្ញុំអាចជួយបានយ៉ាងដូចម្ដេចទៅ បើអ្នកជិតខាងរបស់ខ្ញុំរស់នៅឆ្ងាយនោះ ? »

ម៉ាក់បាននិយាយថា « អ្នកជិតខាងរបស់យើងគឺមនុស្សគ្រប់គ្នានៅជុំវិញខ្លួនយើង » ។ «ដូចជា សមាជិកគ្រួសាររបស់យើងជាដើម » ។

អ៊ីនឌីរ៉ា បានឈ្ងោកមុខចុះ ។ ពេលខ្លះ នាងមិនបានធ្វើល្អចំពោះគ្រួសាររបស់នាងទេ ។

ប៉ុន្តែប្រហែលជាការជួយពួកគេអាចធ្វើឲ្យនាងសប្បាយចិត្ត ដូចដែលប្រធាន ណិលសុន បានមានប្រសាសន៍ ។ នេះវាជាវិធីមួយដែលនាងអាចដើរតាមព្រះយេស៊ូវ ។ នាងចង់សាកល្បងធ្វើវា !



ពេញមួយសប្ដាហ៍ អ៊ីនឌីរ៉ា បានព្យាយាមធ្វើល្អដល់គ្រួសាររបស់នាងកាន់តែខ្លាំង ។ នាងបានលេងជាមួយអាមីណា ។ នាងបានចែករំលែករបស់លេងរបស់នាង ។ នាងបានធ្វើអ្វីដែលម៉ាក់ និងប៉ាបានសុំឲ្យធ្វើ ដោយមិនក្ដួញក្ដែរ ។ នៅពេលដែល អ៊ីនឌីរ៉ា បានជួយគ្រួសារនាង ពួកគេសប្បាយចិត្ត ។ ហើយនោះក៏ធ្វើឲ្យនាងសប្បាយចិត្តផងដែរ ។

ព្យាការីពិតជាមានប្រសាសន៍ត្រូវណាស់ ។ ការជួយអ្នកដទៃពិតជានាំមកនូវភាពរីករាយដល់នាងមែន ! ●



**តើអ្វីខ្លះដែល អ៊ីនឌីរ៉ា បានរៀនពីព្យាការី ?**

១. « The Second Great Commandment » Liahonaខែ វិច្ឆិកា ឆ្នាំ ២០១៩ ទំព័រ ១០០ ។
២. សូមមើល ម៉ាថាយ ២២:៣៧–៣៩ ។